00531008

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

D427/3/15

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

## តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ ដោយអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧/អវតក/កសចស (អបជ ៥៨)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នៃយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORI[GINAL]
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 06 / 2010
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**កាលបរិច្ឆេទ:** ថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០១០

---

**សាធារណៈ(ដោយកោសលុប)**

## សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.សសម្រេចលើ សំណើលើកទី១៨របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE

**សហមេធាវីការពារក្តីជនត្រូវចោទ**
សុន អរុណ
Michel PESTMAN
Victor KOPPE
Andrew IANUZZI

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥៨)

លេខ/No. D273/3/5

Fabienne TRUSSES-NAPROUS
Elizabeth-Joelle RABESANRATANA
Annie DELAHAIE
នី ចាន់ឌី
ឡោ ជុនធី
Silke STUDZINSKY
គង់ ពិសី
ហុង គីមសួន
Pierre-Olivier SUR
យុង ផានិត
ស៊ីន សុវ៉ន
Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
Julien RIVET
Laure DESFORGES
គង់ ហេង
Pascal AUBOIN
ជេត វណ្ណលី
ពេជ អង្គ
Françoise GAUTRY
Isabelle DURAND

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង**

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួល “បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ” សហមេធាវីការពារក្ដី នួន ជា (“ជនត្រូវចោទ” ឬ “ម្ចាស់បណ្ដឹងឧទ្ធរណ៍”) បានដាក់កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ (“ដីកាដែលត្រូវបានជំទាស់”[១] និង “បណ្ដឹងឧទ្ធរណ៍”[២])។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ជនត្រូវចោទបានដាក់“សំណើលើកទីដប់ប្រាំបីសុំបំពេញកិច្ចស៊ើបសួរ”(“សំណើសុំ”)[៣] ដោយក្នុងនោះ ដោយពិចារណាពីតួនាទីពិសេសរបស់លោក [redacted] ដែលជាអតីតសមាជិកមួយរូបរបស់ខ្មែរក្រហមផង និង ជាអ្នកស្ថាបនិកដែលនាំឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំផង ជនត្រូវចោទបានស្នើសុំឱ្យ (១) សម្ភាសន៍ [redacted] (២) ប្រមូលឯកសារពាក់ព័ន្ធនានាដែលគាត់មាន, (៣) ស្វែងរកអត្ថបទស្ដីពីជីវប្រវត្តិរបស់គាត់ជាភាសាអង់គ្លេស និង(៤) ដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារដែលទទួលបានជាលទ្ធផលនៃកិច្ចស៊ើបសួរទាំងបីដែលបានស្នើសុំ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន[៤]។

---

[១] ដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ” ដែលបានចេញជាសម្ងាត់ដោយសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D273/2 (“ដីកាដែលត្រូវបានជំទាស់”)។

[២] បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D273/3/2 (“បណ្ដឹងឧទ្ធរណ៍”)។

[៣] សំណើលើកទីដប់ប្រាំបីសុំបំពេញកិច្ចស៊ើបសួរ ដែលបានដាក់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D273 (“សំណើសុំ”)។

[៤] សំណើសុំ កថាខណ្ឌទី១ និងទី១២។

២. នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) បានចេញដីកាដែលត្រូវបានជំទាស់ដោយបានបដិសេធសំណើសុំខាងលើ[៥]។ ដីកាដែលត្រូវបានជំទាស់ត្រូវបានជូនដំណឹងដល់សហមេធាវីការពារក្តីជនត្រូវចោទនៅថ្ងៃដដែល ហើយសហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានោះនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០។

៣. ការដាក់បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធតាំងពីដំបូងដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះថាមិនត្រូវនឹងពេលវេលា។ បន្ទាប់មក នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចទទួលយកការដាក់បណ្តឹងឧទ្ធរណ៍យឺតពេល ដោយពិចារណាពីការមានជម្ងឺរបស់មេធាវីការពារក្តីដែលមានលក្ខណៈសមស្របបង្កើតបានជាកាលៈទេសៈពិសេស[៦]។

៤. ពុំមានភាគីណាមួយដាក់ចម្លើយតបនៅក្នុងរយៈពេលដែលបានកំណត់នោះទេ។

៥. ម្ចាស់បណ្តឹងឧទ្ធរណ៍បានស្នើសុំឱ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ[៧]។ អង្គបុរេជំនុំជម្រះបានពិចារណាឃើញថា វាជាការសមស្របក្នុងការកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ជនត្រូវចោទ[៨]។

## II. និដ្ឋភាពរួមនៃបណ្តឹងឧទ្ធរណ៍

---

[៥] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៤។

[៦] សេចក្តីសម្រេចលើការទទួលយកការដាក់ឯកសារហួសពេលលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា សម្រេចរបស់ ក.ស.ច.ស លើសំណើលើកទីដប់ប្រាំបីសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០ ឯកសារ D273/3/3 កថាខណ្ឌទី៤។

[៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី២៨។

[៨] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D273/3/4។

00531012



៦. បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ស្របតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង[៩] និងបានលើកឡើងនូវមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ចំនួនបី[១០] ពាក់ព័ន្ធនឹងការបដិសេធរបស់ ស.ច.ស មិនឱ្យដាក់សៀវភៅជីវប្រវត្តិរបស់[redacted] ទៅក្នុងសំណុំរឿង”[១១] ដើម្បីធ្វើការស្តាប់យកចម្លើយពីគាត់[១២] និងដើម្បីព្យាយាមប្រមូលឯកសារទាំងឡាយដែលគាត់មាន ដោយពិចារណាឃើញថា យោងតាម ស.ច.ស វា“មិនទំនងជាគាត់ [[redacted]] បានរក្សាទុកនូវឯកសារពាក់ព័ន្ធនានា លើសពីអ្វីដែលមានស្រាប់នៅក្នុងសំណុំរឿងនោះទេ” ដោយហេតុថាគាត់បានជាប់ឃុំឃាំងអស់រយៈពេលយ៉ាងយូរនៅក្នុង[redacted]ក្រោយឆ្នាំ១៩៧៩[១៣]។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៧. ការដាក់បណ្តឹងឧទ្ធរណ៍យឺតពេលត្រូវបានផ្តល់សុពលភាពឱ្យដោយអង្គបុរេជំនុំជម្រះ។ វិធាន ៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យជនត្រូវចោទធ្វើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះចំពោះដីការបស់ ស.ច.ស ដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរទាំងឡាយ។ ដោយសារម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យស្តាប់យកចម្លើយ[redacted] និងសុំឱ្យប្រមូលឯកសារពាក់ព័ន្ធដែលគាត់មាន វាគឺជាសំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង។ ដោយសារអ្វីដែលត្រូវតវ៉ានៅទីនេះគឺជា ដីកាដែលបានបដិសេធមិនឱ្យបំពេញកិច្ច

---

[៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៨។

[១០] ក្រោមចំណងជើងថា “គំនិតចុងក្រោយ” បណ្តឹងឧទ្ធរណ៍ (កថាខណ្ឌទី២៦ ដល់ទី២៧) លើកឡើងថា ដីកាដែលត្រូវបានជំទាស់គឺជាឧទាហរណ៍ចុងក្រោយ (និងសង្ឃឹមថាចុងក្រោយ) នៃភាពលម្អៀងច្បាស់ ក្រឡែតរបស់ ស.ច.ស ដែលក្នុងនោះ ស.ច.ស ខកខានមិនបានធ្វើការវាយតម្លៃលើសំណើរបស់មេធាវី ការពារក្តីដោយអព្យាក្រិត្យ ដោយយុត្តិធម៌ និងដោយមិនលម្អៀង។ ចំពោះមូលហេតុទាំងឡាយដែលបានបង្ហាញក្រោមមូលដ្ឋាននីមួយៗក្នុងចំណោមមូលដ្ឋានទាំងបីនៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ឃើញថា មិនគាំទ្រដល់ការចោទប្រកាន់នោះឡើយ។

[១១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៩ ដល់ទី១៧។

[១២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១៨ ដល់ទី២២។

[១៣] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៨។ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៤ គ)។



PRE-TRIAL CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C.

ស៊ើបសួរនេះ នោះបណ្តឹងឧទ្ធរណ៍អាចទទួលយកបានដោយយោងតាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង។

៨. ចំពោះសំណើសុំស្វែងរកអត្ថបទជីវប្រវត្តិរបស់[redacted]ជាភាសាអង់គ្លេស និងដាក់ជីវប្រវត្តិនេះចូលក្នុងសំណុំរឿង អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍បានជូនដំណឹងដល់ ស.ច.ស ថា ខ្លួនមានអត្ថបទជីវប្រវត្តិដើមរបស់[redacted]ជាភាសាខ្មែរ ប៉ុន្តែ មិនអាចរកបានអត្ថបទបកប្រែជាភាសាអង់គ្លេស ឬជាភាសាបារាំងនោះទេ[១៤]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា នៅក្នុងផ្នែកពាក់ព័ន្ធ សំណើសុំបានសុំឱ្យ"ស្វែងរកអត្ថបទនៃជីវប្រវត្តិជាភាសាអង់គ្លេស"[១៥] មិនមែនសុំឱ្យដាក់អត្ថបទជីវប្រវត្តិដើមជាភាសាខ្មែរចូលក្នុងសំណុំរឿងនោះទេ។ ផ្នែកចុងក្រោយនៃសំណើសុំនេះមិនបង្កើតបានជា សំណើសុំដាក់អត្ថបទជីវប្រវត្តិដើមជាភាសាខ្មែរចូលក្នុងសំណុំរឿងនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ស.ច.ស ហាក់ដូចជា បានយល់ឃើញថា សំណើបានស្នើសុំដាក់អត្ថបទជីវប្រវត្តិដើមរបស់[redacted]ជាភាសាខ្មែរចូលក្នុងសំណុំរឿង[១៦] ឬក៏អាចថា ស.ច.ស បានពិចារណាឃើញថា សំណើសុំដាក់អត្ថបទបកប្រែជីវប្រវត្តិជាភាសាអង់គ្លេសទៅក្នុងសំណុំរឿង មានន័យថា តម្រូវឱ្យដាក់អត្ថបទដើមជាភាសាខ្មែរចូលក្នុងសំណុំរឿងផងដែរទេ។ ក្នុងករណីណាមួយក៏ដោយ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានធ្វើការតវ៉ាជាមួយនឹង ស.ច.ស លើបញ្ហានេះទេ រីឯអង្គបុរេជំនុំជម្រះនឹងដោះស្រាយនូវភាពអាចទទួលយកបណ្តឹងឧទ្ធរណ៍បាន ទោះបីជាសំណើបានស្នើសុំឱ្យស្វែងរកអត្ថបទនៃជីវប្រវត្តិដើមជាភាសាខ្មែរ ដើម្បីដាក់ទៅក្នុងសំណុំរឿងក៏ដោយ។

៩. នៅក្នុងផ្នែកពាក់ព័ន្ធ វិធាន៥៥(១០)នៃវិធានផ្ទៃក្នុង បានចែងពីសំណើសុំចំនួនពីរប្រភេទដូចខាងក្រោម ដែលជនត្រូវចោទអាចដាក់ជូន ស.ច.ស នៅគ្រប់ពេលវេលានៃការស៊ើបសួរ គឺ "ចេញដីកា"

---

[១៤] សំណើសុំ ជើងទំព័រលេខ ១៤។

[១៥] សំណើសុំ កថាខណ្ឌទី១២ គ)។

[១៦] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៣ និងទី៥។





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

និង "បំពេញកិច្ចស៊ើបសួរណាមួយ" ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ។ ផ្ទុយទៅនឹងសំណើសុំប្រភេទទីពីរ សំណើសុំប្រភេទទីមួយមិនមានន័យថា ការស្វែងរកព័ត៌មានដែលនឹងរួមចំណែកដល់ការកំណត់ការពិតនោះទេ។ ការបែងចែកដាច់ពីគ្នា មានសារៈសំខាន់ណាស់ ពីព្រោះ ទោះបីជាវិធាន ៧៤(៣)(ខ) បានបើកចំហរយ៉ាងច្បាស់លាស់នូវលទ្ធភាពសម្រាប់ជនត្រូវចោទក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ ស.ច.ស ដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរក៏ដោយ វាមិនផ្តល់សិទ្ធិដល់ជនត្រូវចោទឱ្យធ្វើបណ្តឹងឧទ្ធរណ៍ចំពោះការបដិសេធដែលធ្វើឡើងដោយ ស.ច.ស លើសំណើសុំ "ចេញដីកា" ដែលបានចែងដោយវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងនោះឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំដាក់ឯកសារទៅក្នុងសំណុំរឿង ដូចជា សំណើសុំបកប្រែឯកសារជាដើម មិនបង្កើតបានជាសំណើសុំបំពេញកិច្ចស៊ើបសួរនោះទេ។ នៅក្នុងបរិបទនៃបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយសហមេធាវីការពារក្តី អៀង ធីរិទ្ធ អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយអំពីភាពមិនស៊ីសង្វាក់គ្នាដែលអាចកើតមានឡើងរវាងវិធាន ៧៤(៣)(ខ)[១៧] និងវិធាន ៥៥(១០)[១៨] នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះបានសម្រេចថា "ភាពមិនស៊ីសង្វាក់គ្នាដែលអាចកើតចេញមកពីលទ្ធភាពទូទៅក្នុងការប្តឹងឧទ្ធរណ៍ ដែលបានលើកឡើងស្របតាមវិធាន ៥៥(១០)នៃវិធានផ្ទៃក្នុង និងលទ្ធភាពដែលមានដែនកំណត់ក្នុងការប្តឹងឧទ្ធរណ៍ សម្រាប់ជនត្រូវចោទ ស្របតាមវិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង មិនអាចនាំឱ្យមានសេចក្តីសន្និដ្ឋានដូចដែលបានធ្វើដោយសហមេធាវីការពារក្តីស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ"[១៩]។ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង មិនបានចែងពីមធ្យោបាយប្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការស្នើសុំដាក់អត្ថបទជីវប្រវត្តិទៅក្នុងសំណុំរឿងនោះទេ។

---

[១៧] វិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង កំណត់អំពីលទ្ធភាពរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ចំពោះដីកានានាដែលចេញពីក.ស.ច.ស ដែលសម្រេចបដិសេធសំណើសុំ បំពេញកិច្ចស៊ើបសួរ។

[១៨] សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬដែលអាចបានមកដោយសារការធ្វើទារុណកម្ម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ឯកសារ D/130/10/12។

[១៩] ដូចខាងលើ កថាខណ្ឌទី១៧។

១០. ទោះបីជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលផងដែរថា តើអង្គហេតុ និង កាលៈទេសៈនៃផ្នែកនោះនៃបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានការទទួលយកការបកស្រាយទូលំទូលាយ អំពីវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ចំពោះសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តី ដោយយុត្តិធម៌ដែរឬទេ។ ការពិចារណាសំខាន់នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក គឺជាភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដូចមានចែងនៅក្នុងវិធាន ២១.១ នៃវិធានផ្ទៃ ក្នុង ក) ដែលចែងថា “ត្រូវតែមានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាន នូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ”។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ផ្នែកនៃបណ្តឹងឧទ្ធរណ៍នេះលើកឡើង នូវបញ្ហានៃភាព យុត្តិធម៌ ពីព្រោះម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា នៅក្នុងការធ្វើសន្និដ្ឋានថា សៀវភៅស្តីពី ជីវប្រវត្តិ “មិនចាំបាច់ដាក់ទៅក្នុងសំណុំរឿងនោះទេ” ស.ច.ស ខកខានមិនបានទទួលស្គាល់ ភាពពាក់ព័ន្ធនៃសៀវភៅស្តីពីជីវប្រវត្តិនេះដែលអាចដោះបន្ទុក។ អង្គបុរេជំនុំជម្រះយល់ដឹងអំពី លទ្ធភាពសម្រាប់ម្ចាស់បណ្តឹងធ្វើការបង្ហាញភស្តុតាងនៅក្នុងពេលជំនុំជម្រះក្តី[២០]។ ទោះបីជាយ៉ាង ណាក៏ដោយ ដូចដែលបានលើកឡើងដោយជនត្រូវចោទផងដែរ ប្រសិនបើឯកសារត្រូវបានស្នើសុំ ឱ្យដាក់ទៅក្នុងសំណុំរឿងពិតជាមានភស្តុតាងដោះបន្ទុកមែននោះ ការវិភាគឯកសារនោះនឹងធ្វើឱ្យ មានការលើកលែងការចោទប្រកាន់ ទោះជាតែមួយផ្នែក និង/ឬទម្រង់ជាក់លាក់នៃការទទួលខុស ត្រូវ នៅក្នុងដីកាដំណោះស្រាយដែលពាក់ព័ន្ធជាមួយនឹងដីកានេះ ម្ចាស់បណ្តឹងឧទ្ធរណ៍នឹងមិន ចាំបាច់ត្រូវធ្វើការបង្ហាញការការពារខ្លួនក្រោយមកទៀតនោះទេ នៅក្នុងពេលជំនុំជម្រះក្តី។ ជា លទ្ធផល ប្រសិនបើដូច្នេះមែន ការលើកឡើងនេះអាចនឹងមានផលវិបាកធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហេតុដូច្នេះហើយពេលនេះត្រូវធ្វើការ ពិនិត្យលើអង្គសេចក្តីវិញម្តង។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថែមទៀតថា ស.ច.ស បានអនុវត្ត បទដ្ឋានទ្វេរ (double standard) ដោយផ្អែកលើបញ្ហាថាតើសំណើសុំត្រូវបានធ្វើឡើងដោយជន

[២០] ប្រៀបធៀបនឹងវិធាន ៨៤(១) និងទី៩៣ នៃវិធានផ្ទៃក្នុង។

ត្រូវចោទ ឬដោយសហព្រះរាជអាជ្ញា។ ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃការចោទប្រកាន់អំពីភាពលំអៀង និងផលវិបាកដែលអាចកើតមានឡើងទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការត្រឹមត្រូវដែលត្រូវពិចារណាលើផ្នែកនៃអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ។

១២. ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

## IV. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

១៣. អង្គបុរេជំនុំជម្រះនឹងពិនិត្យលើមូលដ្ឋាននីមួយៗនៃបណ្តឹងឧទ្ធរណ៍ជាបន្តបន្ទាប់។ មុនពេលពិនិត្យ អង្គបុរេជំនុំជម្រះរំលឹកថា សេចក្តីសម្រេច (ឬដីកា) លើសំណើសុំបំពេញកិច្ចស៊ើបសួរ គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ និងថា សេចក្តីសម្រេចបែបនេះ អាចត្រូវបានកែប្រែ ប្រសិនបើម្ចាស់បណ្តឹងឧទ្ធរណ៍បង្ហាញថា សេចក្តីសម្រេចដែលត្រូវបានតវ៉ា (១) បានផ្អែកលើការបកស្រាយច្បាប់ជាធរមានមិនត្រឹមត្រូវ ដែលមិនត្រូវបានលើកឡើងនៅក្នុងករណីនេះទេ, (២) បានផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះអំពីអង្គហេតុ ឬ(៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុផលដែលជាការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ ស.ច.ស[២១]។

### ក. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការបដិសេធមិនដាក់អត្ថបទជីវប្រវត្តិទៅក្នុងសំណុំរឿង

[២១] សាលដីកាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារD164/4/13 កថាខណ្ឌទី ២៥ ដល់ទី២៧ ដែលបានអនុម័តការវិនិច្ឆ័យដែលបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICTY នៅក្នុងករណីបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំ *Slobodan Milošević v. Prosecutor*, IT-02-54-AR73.7 ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤។

00531017



១៤. មូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍គឺថា ការបដិសេធមិនឲ្យដាក់សៀវភៅស្ដីពីជីវប្រវត្តិរបស់[redacted] ទៅក្នុងសំណុំរឿង បង្កើតបានជាការរំលោភលើអំណាចឆន្ទានុសិទ្ធិរបស់ ស.ច.ស និងបានផ្អែកលើការអនុវត្តច្បាប់ជាធរមានមិនត្រឹមត្រូវ[២២]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍អះអាងថា នៅក្នុងការសន្និដ្ឋានថា សៀវភៅស្ដីពីជីវប្រវត្តិ "មិនចាំបាច់ដាក់ទៅក្នុងសំណុំរឿងនោះទេ" ស.ច.ស ខកខានមិនបានទទួលស្គាល់ភាពពាក់ព័ន្ធដែលអាចដោះបន្ទុក និងបរិបទនៃឯកសារនេះ។

១៥. ដីកាដែលត្រូវបានជំទាស់មានសំអាងហេតុទាំងឡាយ "ពាក់ព័ន្ធនឹងសំណើសុំដាក់សៀវភៅជាភាសាខ្មែរស្ដីពីជីវប្រវត្តិរបស់[redacted] ទៅក្នុងសំណុំរឿង" ដូចខាងក្រោម ដែល ស.ច.ស បានផ្អែកលើ សំអាងហេតុទាំងនោះ ក្នុងការបដិសេធមិនឲ្យដាក់សៀវភៅនេះទៅក្នុងសំណុំរឿង[២៣]:

- (១) "បន្ទាប់ពីបានធ្វើការពិនិត្យជាជំហានដំបូងលើសៀវភៅនេះ ស.ច.ស យល់ឃើញថា ឯកសារនេះមិនមានតម្លៃជួយដល់ការបង្ហាញការពិត ជាងភស្តុតាងដទៃទៀតដែលមានស្រាប់នៅក្នុងសំណុំរឿងរួចហើយនោះទេ ជាពិសេស ដោយហេតុថា សៀវភៅនេះមិនបានផ្ដល់នូវភស្តុតាងផ្ទាល់ណាមួយទាក់ទងនឹងអង្គហេតុ ដែលឋិតនៅក្រោមការស៊ើបសួរនោះឡើយ អ្នកនិពន្ធសៀវភៅនោះបានយោងទៅលើតែប្រភពមិនផ្ទាល់ដែលអាចរកបានពីក្រៅប្រទេសតែប៉ុណ្ណោះ"[២៤]

- (២) "ការស្រាវជ្រាវបឋមបានបង្ហាញថា សៀវភៅនេះមិនត្រូវបានបោះផ្សាយជាភាសាបារាំង ឬជាភាសាអង់គ្លេសនោះទេ ដូច្នេះ តាមការយល់ឃើញខាងលើ ការដាក់សៀវភៅនេះទាំងមូលចូលក្នុងសំណុំរឿង និងការប្រើប្រាស់ធនធានដើម្បីធ្វើការបកប្រែឯកសារនេះ

---

[២២] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី៩-១៧។

[២៣] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៣។

[២៤] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៣។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ដែលមានរហូតដល់ជាង ៣០០ទំព័រ គឺជាការខ្ជះខ្ជាយធនធានរបស់តុលាការ និងពេលវេលា ដោយឥតប្រយោជន៍ជាមិនខាន"[២៥] និង

- (៣) "ឯកសារនេះបានលើកឡើងអំពីបញ្ហាមួយចំនួនដែលមិនឋិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក នោះទេ។ ទោះបីជាបញ្ហាទាំងនេះអាចជួយដល់ការបង្ហាញការពិតនៅក្នុងកាលៈទេសៈខ្លះក៏ដោយ ប៉ុន្តែនៅក្នុងករណីនេះ ស.ច.ស យល់ឃើញថា សៀវភៅនេះមិនអាចនឹងជួយបំភ្លឺការពិតចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាកើតឡើងនៅក្នុងក្របខណ្ឌយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឬជួយបង្ហាញអំពីធាតុផ្សំនៃបទល្មើស (ជាពិសេសអំពីចេតនាទុច្ចរិត) នៃអំពើទាំងនោះ ឬជួយបង្ហាញអំពីវត្តមាន ឬអវត្តមាននៃរូបភាពនៃឧក្រិដ្ឋកម្មដែលត្រូវបានរៀបចំទុកជាមុននោះឡើយ"[២៦]។

១៦. ដើម្បីទទួលបានជោគជ័យក្នុងការប្តឹងឧទ្ធរណ៍លើបញ្ហានេះនៃដីកាដែលត្រូវបានជំទាស់នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា មូលដ្ឋាននីមួយៗក្នុងចំណោមមូលដ្ឋានទាំងបីសម្រាប់ការធ្វើសេចក្តីសម្រេច មានការភ័ន្តច្រឡំ ឬក៏ថា ប្រសិនបើម្ចាស់បណ្តឹងឧទ្ធរណ៍គ្រាន់តែធ្វើការបង្ហាញភាពពាក់ព័ន្ធនឹងមូលដ្ឋានមួយចំនួនក្នុងចំណោមមូលដ្ឋានទាំងអស់នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវធ្វើការបង្ហាញថា មូលដ្ឋានដែលនៅសល់មិនគាំទ្រដល់ដីកាដែលត្រូវបានជំទាស់នោះទេ។

១៧. ម្ចាស់បណ្តឹងឧទ្ធរណ៍ធ្វើការតវ៉ាទៅលើមូលដ្ឋានទីមួយក្នុងចំណោមមូលដ្ឋានទាំងបី ដែលបានយោងដោយដីកាដែលត្រូវបានជំទាស់ ដោយលើកឡើងថា ពាក់ព័ន្ធជាមួយនឹងការពិនិត្យដែលបានអនុវត្តដោយ ស.ច.ស ដែលឈានដល់ការសន្និដ្ឋានថា ម្ចាស់បណ្តឹងឧទ្ធរណ៍ "ខកខានមិនបាន

---

[២៥] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៣។

[២៦] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៤ និងជើងទំព័រលេខ៣ ដែលបានយោងលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ("ICTR") នៅក្នុងរឿងក្តី *The Prosecutor v. Nahimana et al.* (ICTR-99-52-A), សាលដីកាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌទី៣១៥ និងយោងលើដីកាសម្រេចលើសំណើសុំ ឯកសារ D153, D172, D173, D174, D178 និង D284ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ កថាខណ្ឌទី៩ ឯកសារ D300។

00531019



គិតថាសៀវភៅនេះអាចជួយលាតត្រដាងការពិត ជាងភស្តុតាងដទៃទៀតដែលមានស្រាប់នៅក្នុងសំណុំរឿងរួចហើយ” ម្ចាស់បណ្តឹងឧទ្ធរណ៍យល់ថា ការសន្និដ្ឋានបែបនេះមិនអាចយល់បាន និងមិនអាចការពារបានទេ[២៧]។ អង្គបុរេជំនុំជម្រះឯកភាពជាមួយនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ថា ការពិនិត្យដែលពាក់ព័ន្ធគឺត្រូវផ្តោត ថាតើឯកសារដែលបានលើកឡើងនាំឱ្យរកឃើញការពិតដែរឬទេ ជាជាងថាតើវាអាចជួយលាតត្រដាងការពិត ជាងភស្តុតាងដទៃទៀតដែលមាននៅក្នុងសំណុំរឿងស្រាប់ដែរឬទេ[២៨]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ លើកឡើងនូវបញ្ហាមួយទៀតនៃការសន្និដ្ឋានដែលថា សៀវភៅជីវប្រវត្តិ “មិនបានផ្តល់នូវភស្តុតាងផ្ទាល់ណាមួយទាក់ទងនឹងអង្គហេតុដែលឋិតនៅក្រោមការស៊ើប-សួរនោះឡើយ អ្នកនិពន្ធសៀវភៅនោះបានយោងទៅលើតែប្រភពមិនផ្ទាល់ដែលអាចរកបានពីក្រៅប្រទេសតែប៉ុណ្ណោះ”[២៩]។ ជាថ្មីម្តងទៀត អង្គបុរេជំនុំជម្រះឯកភាពថា សំអាងហេតុនេះខ្វះភាពច្បាស់លាស់។ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលហេតុទីមួយដែលបានគូសបញ្ជាក់ពីដីកាដែលត្រូវបានជំទាស់ មិនគាំទ្រដីកានេះទេ។ អង្គជំនុំជម្រះងាកទៅពិនិត្យលើទឡ្ហីករណ៍ផ្សេងទៀតដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងមូលហេតុទីពីរ និងមូលហេតុទីបី។

១៨. ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថែមទៀតថា ស.ច.ស បានអនុវត្តបទដ្ឋានធូរស្រាលក្នុងការទទួលសំណើរបស់ ក.ស.ព ដែលបានស្នើសុំដាក់បញ្ចូលសៀវភៅនានាដែល យោងតាមម្ចាស់បណ្តឹងឧទ្ធរណ៍ បង្ហាញឱ្យឃើញនូវវិធីសាស្ត្រលម្អៀងរបស់ ស.ច.ស ចំពោះសហមេធាវីការពារក្តី និងបង្កើតបានជាកំហុសអង្គច្បាប់[៣០]។ ម្ចាស់បណ្តឹងឧទ្ធរណ៍ ខកខានមិនបានបង្ហាញអំពីវិធីសាស្ត្រ

[២៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១២។

[២៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១២។

[២៩] ដីកាដែលត្រូវបានជំទាស់ ទំព័រទី៣។

[៣០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១៣ និងទី១៤ ដែលបាននិយាយអំពីដីកាចំនួនពីររបស់ ស.ច.ស ឯកសារ D222/1 (ដែលបានទទួលយកសៀវភៅចំនួន ២២ យោងតាមការលើកឡើងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ “ដោយមិនសមហេតុផល ឬការយោងលើបទដ្ឋានច្បាប់អនុវត្តនៅក្នុងដីកាដែលត្រូវបានជំទាស់”) និង ឯកសារ D313/1 (ដែលបានទទួលយកសៀវភៅចំនួន ១១ ទោះបីជា ស.ច.ស បានរំលឹកថា “សៀវភៅទាំងនោះជា ឯកសារសាធារណៈ ដូចនេះការដាក់សៀវភៅទាំងនោះចូលក្នុងសំណុំរឿងមិនមែនជារឿងសំខាន់

លម្អៀង ដែលខ្លួនបានចោទប្រកាន់នោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ជាការពិត ការលើកឡើងរបស់ ស.ច.ស នៅក្នុងដីកាទីពីរដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានលើកឡើង ដែលថា "សៀវភៅទាំងនេះ គឺជាឯកសារសាធារណៈ ហើយការដាក់ឯកសារទាំងនេះចូលក្នុងសំណុំរឿង មិនមែនជាការចាំបាច់ដាច់ខាតនោះទេ" តែថា"ដើម្បីជួយសម្រួលដល់ភាគីក្នុងការបើកមើល និង ការដកស្រង់ ស.ច.ស. យល់ឃើញថា គប្បីដាក់ឯកសារទាំងនេះចូលក្នុងសំណុំរឿង"[៣១] អាច ផ្ដល់នូវចំណាប់អារម្មណ៍ថា ស.ច.ស បានទទួលយកសៀវភៅទាំងនេះដាក់ទៅក្នុងសំណុំរឿង ដូច ជាថា សៀវភៅទាំងនេះគ្រាន់តែត្រូវបានដាក់នៅក្នុងតារាងមូលដ្ឋានសំអាងផ្លូវច្បាប់ ដើម្បីសម្រួល ដល់ភាគីនានា ក្នុងការយោងលើតារាងនោះប៉ុណ្ណោះ។ ទោះបីជាដីកាដែលបានលើកឡើង មិនបាន ផ្ដល់មូលហេតុពេញលេញចំពោះការទទួលយកសៀវភៅទាំងនេះក៏ដោយ[៣២] ក៏អង្គបុរេជំនុំជម្រះ យល់ឃើញថា ដូចដែលបានលើកឡើងក្នុងសំណើរបស់សហព្រះរាជអាជ្ញា ដែលដីកាបានលើក យោង[៣៣] ស.ច.ស ជឿជាក់ថា សៀវភៅទាំងនេះមានភាពពាក់ព័ន្ធ និងនាំទៅរកការបង្ហាញការពិត យ៉ាងហោចណាស់ ទាក់ទងនឹងការចោទប្រកាន់ចំនួនបីនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពោលគឺ ការប្រព្រឹត្តិបទឧក្រិដ្ឋទាំងឡាយដែលបាន លើកឡើងធាតុផ្សំនៃបទឧក្រិដ្ឋដែលស្ថិតក្នុងយុត្តាធិការ និងបរិបទ ក៏ដូចជាសិទ្ធិអំណាច និង ការចូលរួមរបស់ជនត្រូវចោទផងដែរ[៣៤]។ បញ្ហាដូចគ្នានេះបានកើតឡើង ចំពោះដីកាទីមួយដែល

---

នោះទេ។ តែទោះជាយ៉ាងណាក៏ដោយ ដើម្បីសម្រួលការរកបានរបស់ភាគី និងការដកស្រង់ ស.ច.ស គិតថា សៀវភៅទាំងនោះគួរ តែត្រូវបានដាក់ចូលក្នុងសំណុំរឿង)។

[៣១] ឯកសារ D313/1 កថាខណ្ឌទី២។

[៣២] ពាក់ព័ន្ធនឹងបញ្ហានេះ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង គ្រាន់តែតម្រូវឱ្យមានការផ្ដល់នូវមូលហេតុសម្រាប់ការបដិសេធដីកានានា ប៉ុណ្ណោះ។

[៣៣] ឯកសារ D313 កថាខណ្ឌទី៥ ដល់ទី៦។

[៣៤] យោងលើសំណើសុំដែលបានលើកឡើង សៀវភៅបានសរសេរអំពីរឿងរ៉ាវនៃសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ដែលបាន បង្កើតជាផ្នែកមួយនៃការដណ្ដើមអំណាចរបស់បរិបទនៃបក្សកុម្មុយនីស្តកម្ពុជា កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រួមទាំង តួនាទីរបស់សហរដ្ឋអាមេរិក និងផលប៉ះពាល់នៃការទម្លាក់គ្រាប់បែកយ៉ាងច្រើនរបស់សហរដ្ឋអាមេរិកទៅលើប្រជាជនកម្ពុជា។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

00531021



ម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកថា មិនបានផ្តល់នូវមូលហេតុជាក់លាក់ ចំពោះការយល់ព្រមតាមសំណើសុំដែលបានយោងនោះឡើយ[៣៥]។ ការពិនិត្យឡើងវិញលើសំណើរបស់សហព្រះរាជអាជ្ញា បង្ហាញថា ដូចសំណើពីមុន របស់សហព្រះរាជអាជ្ញាដែរ និងខុសពីសំណើដែលដីកាដែលត្រូវបានជំទាស់បានយកធ្វើជាសំអាង វាមានការវិភាគអំពីសៀវភៅនានាដែលបានស្នើសុំឱ្យទទួលយក និងលើកឡើងយ៉ាងច្បាស់លាស់ អំពីមូលហេតុអ្វីបានជាវានាំទៅរកការបង្ហាញការពិត[៣៦]។

១៩. ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានផ្តល់នូវទឡ្ហីករណ៍ដែលគួរឱ្យជឿជាក់ណាមួយ ដើម្បីតវ៉ាអំពីមូលហេតុទីបីនៅក្នុងដីកាដែលត្រូវបានជំទាស់ ដែលអង្គបុរេជំនុំជម្រះយល់ឃើញថា ផ្តល់មូលដ្ឋានគ្រប់គ្រាន់ក្នុងការគាំទ្រដល់ការបដិសេធមិនទទួលយកសៀវភៅស្តីពីជីវប្រវត្តិរបស់ [redacted] នោះឡើយ។ ជាពិសេស ស.ច.ស បានលើកឡើងថា (១) សៀវភៅនេះមានលើកឡើងពីបញ្ហាមួយចំនួនដែលមិនឋិតនៅក្រោមយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក នោះទេ, (២) សហចៅក្រមយល់ឃើញថា សៀវភៅនេះមិនអាចនឹងជួយបំភ្លឺការពិតបានទេ និង (៣) ក្រុមមេធាវីការពារក្តីមិនបានពន្យល់បកស្រាយអំពី ថាតើសៀវភៅនេះអាចជួយបានប៉ុណ្ណានៅក្នុងការបំភ្លឺអំពីបរិបទនៃការប្រព្រឹត្តិបទល្មើស ដែលត្រូវបានលើកឡើងថា បានកើតឡើងនៅក្នុងយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ក្នុងការកំណត់ ឬបដិសេធធាតុផ្សំបទល្មើស ជាពិសេសចេតនាទុច្ចរិត ឬជួយ

---

សង្គមរបស់អ្នកទីក្រុងដែលបានកើតឡើងរហូតដល់ឆ្នាំ១៩៧៥ និងបានក្លាយជាខ្មាំងសត្រូវផ្នែកវណ្ណៈដែលត្រូវបានសន្មតរបស់ CPK មួយ និងជាក្រុមមួយក្នុងចំណោមក្រុមដែល CPK បានកំណត់ទុកថាជា “ប្រជាជនថ្មី”។ ការធ្វើបាប “ប្រជាជនថ្មី” ដោយរដ្ឋអំណាច CPK និងកម្ពុជាប្រជាធិបតេយ្យ (DK) ។ ទស្សនៈសង្គមវិទ្យា និងនរៈវិទ្យា អំពីសង្គមកម្ពុជា ក្រោមវិធានរបស់ CPK និង DK និងនិន្នាការរបស់ប្រជាជន ដែលមានតម្លៃលើបញ្ហានៃលើកឡើងពីការស្លាប់។ ការជួលរំលំនៃទីក្រុងភ្នំពេញ និងការជម្លៀសអ្នករស់នៅទីក្រុងចេញដោយបង្ខំ ក៏ដូចជា សក្ខីកម្មនានាអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជនស៊ីវិល (ឯកសារ D313 កថាខណ្ឌទី៦)។

[៣៥] ឯកសារ D222/1។

[៣៦] ឯកសារ D222 កថាខណ្ឌទី២ ដល់ទី២២ និងទី២៤ ដល់ទី២៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00531022



បង្ហាញអំពីអត្ថិភាព ឬអវត្តមាននៃរូបភាពនៃឧក្រិដ្ឋកម្មដែលត្រូវបានរៀបចំឡើងជាមុន[៣៧]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាមានអត្ថបទនៃជីវប្រវត្តិជាភាសាខ្មែរ និងដោយបានរាប់សមាជិកជនជាតិកម្ពុជានៃក្រុមរបស់ខ្លួនក៏ដោយ សហមេធាវីការពារក្តីជនត្រូវចោទហាក់ដូចជាភ្លេចធ្វើការវិភាគលើសៀវភៅស្តីពីជីវប្រវត្តិដែលខ្លួនមាននោះ។ ជាការពិត សំណើសុំមិនបានយោងទៅផ្នែកណាមួយនៃសៀវភៅស្តីពីជីវប្រវត្តិនោះទេ ហើយគ្រាន់តែបានលើកឡើងថា "ដោយសារការផ្តាច់ខ្លួន [[redacted]] ដោយចុះចូលជាមួយប្រទេស[redacted]នៅគ្រាដំបូង ការពាក់ព័ន្ធ[redacted] [[redacted] និងតួនាទីពីមុន [redacted])] ក៏ដូចជា"សមាជិកភាពរបស់គាត់ជាមួយខ្មែរក្រហមនៅគ្រាដំបូង និងជាពិសេស ទំនាក់ទំនងរបស់[redacted] [redacted] និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ" "សៀវភៅស្តីពីជីវប្រវត្តិរបស់គាត់ទំនងជាមានព័ត៌មានពាក់ព័ន្ធជាមួយ (ការគូសបញ្ជាក់ដែលត្រូវបានបន្ថែម)" នឹង"ឯកសារ និងភស្តុតាងដទៃទៀតដែលមន្ត្រីវៀតណាមប្រមូលបាននៅក្នុងពេលត្រូតត្រា" និង"របៀបធ្វើការងាររបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ[redacted]"។ ការខកខានមិនបានប្រើប្រាស់ធនធានជាតិកម្ពុជា និងការខកខានមិនបានធ្វើការវិភាគទៅលើមាតិកានៃអត្ថបទដើមនៃជីវប្រវត្តិជាភាសាខ្មែរដែលខ្លួនមាន និងការជ្រើសរើសធ្វើការប៉ាន់ស្មានអំពីសក្តានុពលនៃឯកសារ បានធ្វើឱ្យលក្ខណ្ឌនានានៃសំណើសុំបានជួយគាំទ្រដល់សំអាងហេតុដែលត្រូវបានតវ៉ានៃដីកាដែល ត្រូវបានជំទាស់។

២០. ជាចុងក្រោយ ពាក់ព័ន្ធនឹងសំណើសុំស្វែងរកអត្ថបទបកប្រែសៀវភៅស្តីពីជីវប្រវត្តិ ជាភាសាអង់គ្លេស និងស្នើសុំដាក់អត្ថបទនោះទៅក្នុងសំណុំរឿង ម្ចាស់បណ្តឹងឧទ្ធរណ៍លើកឡើងថា "មិនមែនជាការខ្ជះខ្ជាយធនធានរបស់តុលាការនោះទេ ការបកប្រែ និងការដាក់ភស្តុតាងបរិបទ ដែល

---

[៣៧] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌទី៤ និងលេខជើងទំព័រលេខ៣ ដែលបានយោងលើសាលដីការបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ("ICTR") នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana et al. (ICTR-99-52-A) សាលដីកា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២00៧ កថាខណ្ឌ៣១៥ និងឯកសារ D300 ដីកាសម្រេចលើសំណើសុំ D153, D172, D174, D178 និង D284 ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២00៩ កថាខណ្ឌ ៩។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

មានតម្លៃពិសេសមួយ និងមានសារៈសំខាន់ទៅក្នុងសំណុំរឿង នឹងនាំឲ្យមានការបង្ហាញការពិតបានយ៉ាងច្រើន” និងថា “ការខកខានរបស់ ស.ច.ស ក្នុងការដាក់ឯកសារទៅក្នុងសំណុំរឿង និងការបកប្រែឯកសារនោះមានភាពអយុត្តិធម៌ និងមិនសមហេតុផល ដែលជាការរំលោភបំពាន លើឆន្ទានុសិទ្ធិ”[៣៨]។ ពាក់ព័ន្ធនឹងបញ្ហានេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដោយយល់ឃើញថា សៀវភៅនេះមិនចាំបាច់ដាក់ទៅក្នុងសំណុំរឿងនោះ ដីកាដែលត្រូវបានជំទាស់បានលើកឡើងបន្តទៀតថា “ប្រសិនបើក្រុមមេធាវីការពារក្តីស្នើសុំដាក់ខ្លឹមសារដកស្រង់ណាមួយដែលខ្លួនយល់ថា ជាភស្តុតាងដោះបន្ទុកដោយមានភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសាអង់គ្លេស ឬបារាំងដូចដែលកំណត់នៅក្នុងមាត្រា៧.១នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតនឹងធានាថា ឯកសារនោះនឹងនឹងត្រូវបញ្ចូលទៅក្នុងសំណុំរឿងសម្រាប់គ្រប់ភាគីប្រើប្រាស់នៅក្នុងដំណើរការនីតិវិធីនាពេលខាងមុខ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ស្របចំពោះសំណើសុំក្នុងការធ្វើដូច្នេះ”[៣៩]។ ដោយយល់ឃើញថា ពុំមានកំហុសនៅក្នុងសេចក្តីសម្រេចរបស់ ស.ច.ស ក្នុងការមិនទទួលយកសៀវភៅស្តីពីជីវប្រវត្តិដាក់ចូលទៅក្នុងសំណុំរឿងនោះ អង្គបុរេជំនុំជម្រះមិនឯកភាពថា ស.ច.ស បានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការមិនទាមទារឲ្យធ្វើការបកប្រែអត្ថបទជាភាសាអង់គ្លេស ដោយប្រើប្រាស់ធនធានរបស់ អ.វ.ត.ក នោះ។

២១. អាស្រ័យហេតុនេះ មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធចោល។

## ខ. <u>មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការបដិសេធមិនស្តាប់ចម្លើយ</u> [redacted]

[៣៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១៧។

[៣៩] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌទី៥។

២២. ការចោទប្រកាន់ក្រោមមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍គឺថា ការបដិសេធមិនស្តាប់ចម្លើយ[redacted] បង្កើតបានជាការរំលោភលើឆន្ទានុសិទ្ធិរបស់ ស.ច.ស និងជាកំហុសអង្គច្បាប់។

២៣. កថាខណ្ឌទី៦ និងទី៧ នៃដីកាដែលត្រូវបានជំទាស់ ដែលទាក់ទងនឹងសំណើសុំស្តាប់ចម្លើយ[redacted] បានលើកឡើងថា:

> ទាក់ទងជាមួយនឹងសំណើសុំស្តាប់ចម្លើយ[redacted] សហចៅក្រមស៊ើបអង្កេតសូមរំលឹកថា ដើម្បីធ្វើការសម្រេចឲ្យមានការស្តាប់ចម្លើយបុគ្គលណាមួយដែលមានឈ្មោះនៅក្នុងសំណើសុំ ចាំបាច់ត្រូវធ្វើការវាយតម្លៃទៅលើព័ត៌មានដែលបុគ្គលនោះអាចផ្តល់ឲ្យ ជាមួយនឹងឯកសារសំណុំរឿងទាំងមូល និងអំពីទំហំដែលព័ត៌មាននោះអាចជួយដល់ការបង្ហាញការពិត។ ការវាយតម្លៃនេះក៏ត្រូវពិចារណាផងដែរអំពីតម្រូវការឲ្យមានដំណើរការនីតិវិធីមួយឆាប់រហ័ស ធានាបាននូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ជាពិសេសសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយមិនមានការយឺតយ៉ាវ។
>
> នៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស្វះស្វែងរៀបចំឲ្យមានការស្តាប់ចម្លើយនៅក្នុងដំណាក់កាលនេះ នឹងមិនអាចជួយសម្រួលដល់ការបង្ហាញការពិតទាក់ទងនឹងបញ្ហាទាំងនេះ ដើម្បីជាហេតុផលក្នុងការផ្តល់យុត្តិកម្មលើដំណើរការយឺតយ៉ាវនៃនីតិវិធី លើសពីអ្វីដែលមាននៅក្នុងសំណុំរឿងរួចមកហើយនោះទេ៖ ដោយហេតុថា (i) [redacted] មិនបានមានវត្តមាននៅក្នុងប្រទេសកម្ពុជាទាំងមុនពេល ឬក្នុងអំឡុងពេលនៃយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ដូច្នេះគាត់ទំនងជាមិនអាចផ្តល់នូវព័ត៌មានដើមទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជានោះទេ, (ii) នៅក្នុងសំណុំរឿង មានឯកសារស្រាវជ្រាវប្រវត្តិសាស្ត្រ និងភស្តុតាងគ្រប់គ្រាន់ ដែលទាក់ទងនឹងបញ្ហាដែលលើកឡើងនៅក្នុងសំណើសុំនេះ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

២៤. ម្ចាស់បណ្ដឹងឧទ្ធរណ៍ធ្វើការតវ៉ាទៅលើការសន្និដ្ឋាននានា ដែលគាំទ្រសំអាងហេតុរួមដែលបានគូស បញ្ជាក់ខាងលើ[៤០]។ ជាដំបូង ម្ចាស់បណ្ដឹងឧទ្ធរណ៍លើកឡើងថា ស.ច.ស មិនយល់ចំណុចចង់បាន នៃសំណើសុំ ដោយយល់ថា "[redacted] មិនមានវត្តមាននៅក្នុងប្រទេសកម្ពុជាទាំង មុនពេល ឬក្នុងអំឡុងពេលនៃយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក, ដូច្នេះ គាត់ទំនងជាមិន អាចផ្ដល់នូវព័ត៌មានដើមទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនៅ ក្នុងប្រទេសកម្ពុជានោះទេ"[៤១]។ យោងតាមម្ចាស់បណ្ដឹងឧទ្ធរណ៍ ជំនួសឱ្យការស្នើសុំព័ត៌មានពី [redacted] ពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋនានាជាក់លាក់ សំណើសុំស្នើសុំឱ្យស្វែងរក "ការយល់ដឹងលើបញ្ហាបរិបទជាច្រើន(អាចថាដោះបន្ទុក)" ដែលបានលើកឡើងនៅកថាខណ្ឌ ១០ នៃបណ្ដឹងឧទ្ធរណ៍ និងអង្គហេតុដែលថា ការយល់ដឹងបែបនេះបានកើតមាននៅប្រទេសវៀតណាម មិនមែននៅក្នុងប្រទេសកម្ពុជាទេ មិនអាចចាត់ទុកការយល់ដឹងទាំងនេះថាមិនពាក់ព័ន្ធបានទេ[៤២]។

២៥. ម្ចាស់បណ្ដឹងឧទ្ធរណ៍មានភាពត្រឹមត្រូវក្នុងការលើកឡើងថា សំអាងហេតុរបស់ដីកាដែលត្រូវបាន ជំទាស់ដែលថា "[redacted] មិនបានមានវត្តមាននៅក្នុងប្រទេសកម្ពុជាទាំងមុនពេល ឬក្នុងអំឡុងពេលនៃយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក, ដូច្នេះ គាត់ទំនងជាមិនអាចផ្ដល់ នូវព័ត៌មានដើមទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងនៅក្នុងប្រទេស កម្ពុជានោះទេ" ខកខានមិនបានលើកឡើងនូវមូលហេតុច្បាស់លាស់ ដែលបានលើកឡើងច្បាស់នៅ ក្នុងសំណើសុំដើម្បីធ្វើយុត្តិកម្មចំពោះការស្ដាប់ចម្លើយ[redacted] គឺថា (១) គាត់គឺជា "មនុស្សដ៏សក្ដិសមបំផុតក្នុងការផ្ដល់ព័ត៌មាន ទាក់ទិនទៅនឹងអរិភាពជាមួយប្រទេសវៀតណាម ដែលត្រូវបានសន្មតនោះ" និង"គាត់ទំនងជាអាចផ្ដល់ព័ត៌មានមានសារៈប្រយោជន៍ ទាក់ទងទៅនឹង

---

[៤០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី១៨ ដល់ទី២២ ដែលបានយោងលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌទី៧។

[៤១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី១៩។

[៤២] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី១៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00531026



ឯកសារនានា និងភស្តុតាងដទៃទៀតដែលមន្ត្រីវៀតណាមប្រមូលបានក្នុងអំឡុងពេលត្រួតត្រា"[៤៣] និងថា (២) គាត់"[redacted]"[៤៤]។ ដើម្បីទទួលបានជោគជ័យក្នុងការធ្វើការតវ៉ាចំពោះការបដិសេធមិនស្តាប់ចម្លើយរបស់[redacted] នៅក្នុងបណ្តឹងឧទ្ធរណ៍ ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបង្ហាញថា មូលហេតុទីពីរដែលដីកាដែលត្រូវបានជំទាស់បានយោង (ពោលគឺថា "មានចំនួននៃការស្រាវជ្រាវ និងភស្តុតាងគ្រប់គ្រាន់ហើយដែលបានដាក់នៅក្នុងសំណុំរឿងរួចហើយ" ពាក់ព័ន្ធនឹងបញ្ហានេះ) ក៏មានការភ័ន្តច្រឡំផងដែរ ឬក៏មូលហេតុនេះតែឯងមិនគាំទ្រដីកា ដែលត្រូវបានជំទាស់នោះទេ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ពាក់ព័ន្ធនឹងអ្វីដែលថា[redacted] គ្មានព័ត៌មានបរិបទដោះបន្ទុកនោះ ម្ចាស់បណ្តឹងឧទ្ធរណ៍គ្មានបំណងបង្ហាញចំណុចនេះទេ។

២៦. ជាការពិត ម្ចាស់បណ្តឹងឧទ្ធរណ៍បានកំណត់ការតវ៉ារបស់ខ្លួនតែចំពោះសំអាងហេតុខាងលើទៅក្នុងកម្រិតមួយថា ភស្តុតាង[redacted] មានលក្ខណៈអាចដោះបន្ទុក[៤៥]។ ដើម្បីគាំទ្រដល់ការតវ៉ានេះ ម្ចាស់បណ្តឹងឧទ្ធរណ៍បានផ្អែកលើសំអាងហេតុ របស់អង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេច SMD ដែលថា ការផ្អែកលើ"គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាង" របស់ ស.ច.ស ដើម្បីជៀសវាងការប្រមូល និងការវាយតម្លៃលើសម្ភារៈដែលអាចដោះបន្ទុក បង្កើតបានជាការភ័ន្ត

---

[៤៣] សំណើសុំ កថាខណ្ឌទី១១ ដែលបានយោងលើការភៀសខ្លួនទៅប្រទេសវៀតណាមដំបូងរបស់[redacted] ការពាក់ព័ន្ធ[redacted] ដើម្បីគាំទ្រដល់ទឡ្ហីករណ៍នេះ។

[៤៤] សំណើសុំ កថាខណ្ឌទី១១ ដែលបានយោងលើសមាជិកភាពដំបូងរបស់[redacted] ជាមួយខ្មែរ ក្រហម និង ជាពិសេស[redacted] ដើម្បីគាំទ្រដល់ទឡ្ហីករណ៍នេះ។

[៤៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី២០។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

ច្រឡំលើអង្គច្បាប់[៤៦]។ អង្គបុរេជំនុំជម្រះឯកភាពតាមការបកស្រាយរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍អំពីសេចក្ដីសម្រេច SMD ពាក់ព័ន្ធនឹងភស្ដុតាងដោះបន្ទុក។ ប្រសិនបើសំណើសុំត្រូវបានគាំទ្រ ដោយ *មូលហេតុបឋម(prima facie)* ដែលនាំឱ្យជឿជាក់ថា [redacted] មានព័ត៌មានដែលអាចមានលក្ខណៈដោះបន្ទុកចំពោះជនត្រូវចោទ ស.ច.ស អាចនឹងមានកាតព្វកិច្ចយល់ព្រមតាមសំណើសុំ។ យោងតាមម្ចាស់បណ្ដឹងឧទ្ធរណ៍ សំណើសុំនេះត្រូវបានគាំទ្រដោយ*មូលហេតុបឋម*នេះ[៤៧]។ អង្គបុរេជំនុំជម្រះមិនជឿជាក់ថា វាដូច្នេះទេ។ ក្រៅពីការយោងទូទៅលើវិធាន ៥៥(៥)នៃវិធានផ្ទៃក្នុង និងកាតព្វកិច្ចរបស់ ស.ច.ស ក្នុងការដឹកនាំកិច្ចស៊ើបសួរដោយអនាគតិនោះថាតើភស្ដុតាងណា ជាភស្ដុតាងដាក់បន្ទុក ឬជាភស្ដុតាងដោះបន្ទុកនោះ[៤៨] នៅក្នុងសំណើសុំការយោងតែលើភស្ដុតាងដែលបានសង្ឃឹមទុកថា អាចមានលក្ខណៈដោះបន្ទុក មានតែសៀវភៅស្ដីពីជីវប្រវត្តិ និងមិនទាក់ទងជាមួយនឹងព័ត៌មាន ដែលត្រូវទទួលបានតាមរយៈការស្ដាប់ចម្លើយ [redacted] នោះទេ[៤៩]។

២៧. អាស្រ័យហេតុនេះ មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះត្រូវបានបដិសេធចោល។

**គ. មូលដ្ឋានទីបីនៃបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការខ្វះការព្យាយាមប្រមូលឯកសារពី [redacted]**

---

[៤៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២០ ដែលបានយោងលើសាលដីកាសាធារណៈលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្ដុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ ERN 00402746-00402762 ("សាលដីកា SMD") កថាខណ្ឌទី ៣៦ ដល់ទី៣៨ ។ សូមមើលផងដែរ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២១។

[៤៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២០។

[៤៨] សំណើសុំ កថាខណ្ឌទី៩។

[៤៩] សំណើសុំ កថាខណ្ឌទី១១ ប្រយោគចុងក្រោយគេ។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

២៨. ការចោទប្រកាន់ក្រោមមូលដ្ឋានទីបីនៃបណ្ដឹងឧទ្ធរណ៍គឺថា ស.ច.ស បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួននៅក្នុងការអះអាងថា វា"ទំនងជាមិនអាចថា [[redacted]] មានឯកសារពាក់ព័ន្ធនោះទេ បន្ថែមពីលើឯកសារដែលមានរួចហើយនៅក្នុងសំណុំរឿង ដើម្បីធ្វើយុត្តិកម្មចំពោះការស្ដាប់ចម្លើយរបស់គាត់" ដោយសារថា គាត់បានជាប់ឃុំឃាំងអស់រយៈពេលយ៉ាងយូរនៅប្រទេស [redacted] ក្រោយឆ្នាំ១៩៧៩[៥០]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍លើកឡើងថា ទោះបីជា [redacted] អាចថា បានជាប់នៅក្នុងមន្ទីរឃុំឃាំងក្រោយឆ្នាំ១៩៧៩ក៏ដោយ [redacted] និងអាចមានសិទ្ធិច្រើនក្នុងការពិនិត្យមើលលើឯកសារផ្លូវការនានា និងសម្ភារៈផ្សេងទៀតដែលមន្ត្រីវៀតណាមប្រមូលបានក្នុងអំឡុងពេលត្រួតត្រារបស់ពួកគេលើប្រទេសកម្ពុជា ហើយគាត់អាចរកវិធីរក្សាទុកឯកសារទាំងនេះដោយសុវត្ថិភាពមុនពេល [redacted][៥១]។ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានធ្វើការតវ៉ា ជាពិសេសលើអង្គហេតុដែលថា ស.ច.ស មិនបានចាត់វិធានការណាមួយក្នុងការសួរ [redacted] ដោយផ្ទាល់ ថាតើគាត់មានឯកសារទាំងនេះដែរឬទេ[៥២]។

២៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្ដីជនត្រូវចោទមិនបានបង្ហាញថា ខ្លួនបានធ្វើកិច្ចស៊ើបសួរបឋមចំពោះបញ្ហា ថាតើ [redacted] អាច ឬមិនអាចមានឯកសារទាំងអស់នេះទេ[៥៣]។ សំខាន់ជាងនេះទៀត ខុសពីសំណើសុំស្ដាប់ចម្លើយរបស់ [redacted] ដែលបានពន្យល់អំពីមូលហេតុ ហេតុអ្វីបានជាម្ចាស់បណ្ដឹងឧទ្ធរណ៍ជឿជាក់ថា [redacted]

---

[៥០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២៣ ដល់ទី២៥។

[៥១] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២៣។

[៥២] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី២៤។

[៥៣] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេស ចំពោះការទាត់ចោលសំណើសុំស្ដាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន, ០០២/១៩-០៩-២០០៧-អ.វ.ត.ក-កសចស (អបជ៤៥) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០, សម្អាត់, ទំព័រ១៥, ឯកសារ D315/1/5។

ជាអ្នកអាចផ្តល់ព័ត៌មានបរិបទសំខាន់ទាក់ទងនឹងឯកសារ និងសម្ភារៈផ្សេងទៀត ដែលមន្ត្រីវៀតណាមបានប្រមូលនៅក្នុងពេលត្រួតត្រានោះ[៥៤] សំណើសុំមិនបានផ្តល់មូលហេតុ ហេតុអ្វីបានជាម្ចាស់បណ្តឹងឧទ្ធរណ៍ជឿជាក់ថា [redacted] អាចមានឯកសារដែលពាក់ព័ន្ធទាំងនេះឡើយ[៥៥]។ មូលហេតុដែលខ្វះខាតទាំងនេះបានបង្ហាញឡើងតាំងពីគ្រាដំបូងនៃការប្តឹងឧទ្ធរណ៍ ដូចនេះហើយ មិនអាចបង្ហាញពីការភ័ន្តច្រឡំរបស់ ស.ច.ស នៅពេលដែល ស.ច.ស បានធ្វើការសន្និដ្ឋានថា [redacted] ទំនងជាមិនមានឯកសារដែលពាក់ព័ន្ធណាមួយឡើយ។ ហេតុដូច្នេះ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានបដិសេធចោល។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ÷**

១.**ប្រកាសថា** បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់ និង

២.**បដិសេធ** បណ្តឹងឧទ្ធរណ៍លើអង្គសេចក្តី។

**ភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING **ន័យ ធុល** Catherine MARCHI-UHEL **ហួត វុទ្ធី** **ប្រាក់ គីមសាន**

[៥៤] សំណើសុំ កថាខណ្ឌទី១១។

[៥៥] សំណើសុំ កថាខណ្ឌទី១២។